អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**សេចក្តីប្រកាសព័ត៌មាន**

**សេចក្តីសន្និដ្ឋានបញ្ចប់នៃកិច្ចប្រជុំពេញអង្គលើកទី៧ របស់ អវតក**

**នៅថ្ងៃអង្គារ៍ ទី៩ ខែកុម្ភៈ ឆ្នាំ២០១០**

កិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបញ្ចប់នៅថ្ងៃនេះ ដោយបានធ្វើការអនុម័តវិសោធនកម្មវិធានផ្ទៃក្នុងមួយចំនួន ដែលត្រូវបានតាក់តែងឡើងដើម្បីធានា នូវប្រសិទ្ធិភាព និងភាពងាយស្រួលដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធី អ.វ.ត.ក ។ រហូតមកដល់ថ្ងៃនេះ អង្គភាពជនរងគ្រោះ បានទទួលការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនប្រហែល ៤០០០។ វាច្បាស់ណាស់ថា បទប្បញ្ញត្តិច្បាប់ដែលមានស្រាប់ក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនត្រូវបានតាក់តែងឡើងដើម្បីផ្តល់ដំណោះស្រាយដល់ការចូលរួមជាលក្ខណៈបុគ្គលផ្ទាល់ខ្លួនដោយជនរងគ្រោះក្នុងវិសាលភាពនេះទេ ។ ចំនួនអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភាពស្មុគស្មាញ ទំហំ និងលក្ខណៈពិសេសដទៃទៀតនៃដំណើរការនីតិវិធីរបស់អ.វ.ត.ក ធ្វើឲ្យមានភាពចាំបាច់ដើម្បីអនុម័តនូវប្រពន្ធ័ថ្មីមួយ  នៃការតំណាងជនរងគ្រោះនៅក្នុងដំណាក់កាលជំនុំជម្រះនិងបណ្តឹងឧទ្ធរណ៍ ។ បទប្បញ្ញត្តិថ្មីដែលបានអនុម័តរួចហើយនេះ មានបំណងធ្វើឲ្យមានតុល្យភាពនូវរាល់សិទ្ធិរបស់ភាគីទាំងអស់ ធានានូវសមត្ថភាពរបស់អ.វ.ត.ក ដើម្បីសម្រេចឲ្យបាននូវអណត្តិរបស់ខ្លួន ព្រមជាមួយគ្នានឹងការរក្សាឲ្យបាននូវការចូលរួមរបស់ ដើមបណ្តឹងរដ្ឋប្បវេណី និងពង្រឹងគុណភាពនៃការតំណាង ដើមបណ្តឹងរដ្ឋប្បវេណី ។

ដើម្បីផ្តល់ផលប្រយោជន៍ឲ្យបានកាន់តែទូលំទូលាយជាងមុនដល់ជនរងគ្រោះ កិច្ចប្រជុំពេញអង្គលើកទី៧ បានផ្តល់អំណាចដល់អង្គភាពជនរងគ្រោះ (ដែលមានឈ្មោះថ្មីជាអង្គភាពគាំពារជនរងគ្រោះ) ក្នុងការបង្កើត និងអនុវត្តកម្មវិធី និងវិធានការថ្មីៗដែលកើតឡើងនៅក្រៅកិច្ចដំណើរការនីតិវិធីតុលាការជាផ្លូវការ។ វិធានការទាំងនេះអាចរួមមានសេវាកម្មដែលមានចំនួនច្រើនជាងមុន ព្រមទាំងការដាក់បញ្ចូលជនរងគ្រោះឲ្យបានច្រើនគ្រប់ទិសទីច្រើនជាងមុនមិនត្រឹមតែ (បុគ្គលដែលត្រូវទទួលស្គាល់) (បុគ្គលមួយចំនួនតូចដែលមានគុណសម្បត្តិអាចត្រូវគេទទួលស្គាល់ ) ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនៅចំពោះមុខអ.វ.ត.ក ។ វិសោធនកម្មវិធានផ្ទៃក្នុងនេះបញ្ជាក់យ៉ាងច្បាស់ថាវិធានការទាំងឡាយដែលអាចនឹងត្រូវបង្កើតឡើងដោយមានកិច្ចសហការជាមួយទីភ្នាក់ងាររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលនៅក្រៅអ.វ.ត.ក ដែលផ្តល់លទ្ធភាពក្នុងការបង្កើតនូវកម្មវិធីទូលំទូលាយជាងមុនដែលអាចសម្រេចបានក្នុងរង្វង់សមត្ថភាព និងធនធានដែលមាននៅក្នុងអ.វ.ត.ក។

វិសោធនកម្មផ្សេងៗទៀតដែលត្រូវបានអនុម័តក្នុងអំឡុងកិច្ចប្រជុំពេញអង្គលើកទី៧នេះ ត្រូវបានតាក់តែងឡើងដើម្បីធ្វើឲ្យមានភាពងាយស្រួលដល់ការតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក ។ វិធានដែលត្រូវបានធ្វើវិសោធនកម្មទាំងនេះ រួមមានការបង្កើតសហមេធាវីនាំមុខដើមបណ្តឹង

រដ្ឋប្បវេណីដែលមានការទទួលខុសត្រូវជាចុងក្រោយចំពោះការផ្តល់អំណះអំណាង យុទ្ធសាស្ត្រ និងការតំណាងជារួមនៅក្នុងតុលាការនូវផលប្រយោជន៍នៃបណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ។ វិធានដែលត្រូវបានធ្វើវិសោធនកម្មទាំងនេះ គូសបញ្ជាក់ថាសហមេធាវីនាំមុខត្រូវស្នើសុំយោបល់ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឬ ដើមបណ្តឹងរដ្ឋប្បវេណីជាក្រុម) និងប្រឹងប្រែងឲ្យមានការព្រមព្រៀងជាឯកឆន្ទក្នុងការសម្របសម្រួលការតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលជំនុំជម្រះ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ អាចយល់ព្រមផ្តល់ការគាំទ្រដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការតំណាងផលប្រយោជន៍នៃក្រុមបណ្តុំ។ ការគាំទ្រទាំងនេះដែលនឹងត្រូវសម្របសម្រួលដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចរួមបញ្ចូលទាំងការដាក់សារណាដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងការស្តាប់ចម្លើយកូនក្តីរបស់ខ្លួន និងសាក្សីក្នុងតុលាការ។

ខណៈពេលដែលទទួលការគាំទ្រផ្នែករដ្ឋបាលពីតុលាការ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងស្ថិតនៅក្នុងអង្គភាពមួយដាច់ដោយឡែកនៅក្នុងអ.វ.ត.ក ដែលត្រូវបានបង្កើតឡើងដើម្បីធានាឯករាជ្យភាពរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ព្រមជាមួយនឹងការផ្តល់លទ្ធភាពជាក់ស្តែងដល់អង្គភាពគាំពារជនរងគ្រោះដើម្បីបំពេញការទទួលខុសរបស់ខ្លួនឲ្យកាន់តែប្រសើរឡើង ដើម្បីបង្កើតកម្មវិធីថ្មីសំដៅទៅដល់ការគាំពារជនរងគ្រោះ (ខាងលើ) ។ បន្ថែមពីនេះទៀត វិធានដែលត្រូវបានធ្វើវិសោធនកម្ម បានអនុម័តវិធានការថវិកា និងរដ្ឋបាលដែលបង្កើនកម្រិតសមស្របមួយនៃមូលនិធិតុលាការសម្រាប់តំណាងផ្នែកច្បាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី។
វាត្រូវបានគេរំពឹងថានឹងធ្វើឲ្យប្រសើរឡើងនូវការចូលរួមប្រកបដោយអត្ថន័យរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងដទៃទៀតក្នុងពេលអនាគត។ វិធានដែលត្រូវបានអនុម័ត បញ្ជាក់បន្ថែមយ៉ាងច្បាស់ថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ (ទាំងអ្នកត្រូវបានផ្តល់មូលនិធិដោយតុលាការ ឬខាងក្រៅ) អាចទទួលបានការគាំទ្រផ្នែករដ្ឋបាលពីអ.វ.ត.ក បាន។

ដោយពេលវេលាមានកំណត់ កិច្ចប្រជុំពេញអង្គលើកទី៧ បានផ្តោតការយកចិត្តទុកដាក់ចំពោះវិសោធនកម្មដែលមានភាពចាំបាច់ ដែលអនុញ្ញាតឲ្យអ.វ.ត.ក ដំណើរការនីតិវិធីសម្រាប់រយៈពេលប៉ុន្មានខែខាងមុខ។ ហេតុដូច្នេះ កិច្ចប្រជុំពេញអង្គនេះ បានអនុម័តវិធានការមួយចំនួនដើម្បីធានាថាបញ្ហានានាទាក់ទងនឹងការទទួលយកនូវការដាក់ពាក្យរបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ នឹងត្រូវសម្រេចក្នុងដំណាក់មុនពេលជំនុំជម្រះដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះរៀងៗខ្លួន។

កិច្ចប្រជុំពេញអង្គ បញ្ជាក់អះអាងឡើងវិញនូវទស្សនៈទាននៃការដាក់ការទាមទារសំណងសមូហភាព និងផ្លូវចិត្តតែមួយ តាំងនាមឲ្យបណ្តុំនៃដើមបណ្តឹងរដ្ឋប្បវេណី ។ វិធានមួយចំនួនត្រូវបានធ្វើការកែសម្រួលដោយកិច្ចប្រជុំពេញអង្គដើម្បីផ្តល់ព័ត៌មានលម្អិតនៃការទាមទារនេះ ។ លើសពីនេះទៅទៀត វិសោធនកម្មសំខាន់ៗមួយចំនួន នឹងត្រូវធ្វើឡើងនៅដំណាក់កាលក្រោយ ។

វិសោធនកម្ម ដែលត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គលើកទី៧នេះ មិនត្រូវបានអនុវត្តសម្រាប់សំណុំរឿង០០១ ទេ។


លោក **រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 156
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោក **ឌីម សុវណ្ណារ៉ុំ**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855(0) 12 488 0៩៤
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855(0) 12 488 023
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6169
សារអេឡិចត្រូនិច olsenl@un.org

លោកស្រី **យូកូ មេដា**
មន្ត្រីផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 319
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6139
សារអេឡិចត្រូនិច maeday@un.org